ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៧៣១៤ សរ.ក

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ថ្ងៃ ..សុក្រ ៣រោច ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ..២៩... ខែ កក្កដា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃផ្គត់ផ្គង់ សម្ភារថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ និងសម្ភារសម្រាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ ជូនស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ, បាត់ដំបង, កំពង់ឆ្នាំង, កំពង់ស្ពឺ, កំពត, កោះកុង, មណ្ឌលគិរី, ព្រះវិហារ, ព្រៃវែង, ពោធិ៍សាត់, រតនគិរី, សៀមរាប, ព្រះសីហនុ, ស្ទឹងត្រែង, ស្វាយរៀង, តាកែវ, ឧត្តរមានជ័យ, កែប, ប៉ៃលិន និងត្បូងឃ្មុំ

ក្រសួងមហាផ្ទៃ សូមជម្រាបជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក (គិតទាំងសហគ្រាសឯកត្តបុគ្គល)ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ៖ ក្រសួងមហាផ្ទៃនឹងដាក់ឱ្យដេញថ្លៃប្រកួតប្រជែងជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ សម្ភារថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ និងសម្ភារសម្រាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ ជូនស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ, បាត់ដំបង, កំពង់ឆ្នាំង, កំពង់ស្ពឺ, កំពត, កោះកុង, មណ្ឌលគិរី, ព្រះវិហារ, ព្រៃវែង, ពោធិ៍សាត់, រតនគិរី, សៀមរាប, ព្រះសីហនុ, ស្ទឹងត្រែង, ស្វាយរៀង, តាកែវ, ឧត្តរមានជ័យ, កែប, ប៉ៃលិន និងត្បូងឃ្មុំ ។

ក្រសួងមហាផ្ទៃ បានរៀបចំឯកសារដេញថ្លៃ (សៀវភៅបន្ទុក) សម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម ដែលមានអាសយដ្ឋានស្ថិតនៅអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ ចាប់ពីថ្ងៃទី ...៣១..... ខែ ...កក្កដា....... ឆ្នាំ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៩៧ ៦៦ ៧ ៧ ៨៥៦) ។

ឯកសារដេញថ្លៃ (សៀវភៅបន្ទុក) ដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម ក្រសួងមហាផ្ទៃ យ៉ាងយូរបំផុតត្រឹមវេលាម៉ោង......០៩ : ០០.........នាទី ថ្ងៃទី...២៩... ខែ...សីហា... ឆ្នាំ២០១៩ ។

ការបើកកញ្ចប់ឯកសារដេញថ្លៃ នឹងប្រព្រឹត្តទៅនៅសាលប្រជុំក្រសួងមហាផ្ទៃ វេលាម៉ោង..០៩ : ០០....នាទី ថ្ងៃទី...២៩.... ខែ....សីហា.. ឆ្នាំ២០១៩ ។

-ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

-ក្រុមហ៊ុន ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មក្រសួងមហាផ្ទៃ ដើម្បីទិញឯកសារដេញថ្លៃ (សៀវភៅបន្ទុក) និងសាកសួរព័ត៌មាននានាដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

ចម្លងជូន ៖
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
"អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ"